# ជំពូកទី០១

# សេចក្តីផ្តើម

## ១.១. លក្ខណៈទូទៅនៃគំរោង

ដើម្បីសំរេចឱ្យបាននូវការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងការជំរុញឱ្យមានកំនើនសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើនដែលក្នុងនោះរួមមាន យុទ្ធ-សាស្ត្រក្នុងការទាក់ទាញវិនិយោគឯកជនក្នុង និងក្រៅប្រទេសជាដើម។ ច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (2006) បានផ្តល់ឱ្យអ្នកវិនិយោគនូវការលើកទឹកចិត្តជាច្រើនដូចជា ការទទួលបានការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធគយ និងពន្ធអាករដែលនេះ គឺជាកត្តាលីករមួយយ៉ាងសំខាន់ក្នុងការទាក់ទាញ និងនាំឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃការចូលមកវិយោគលើគ្រប់វិស័យ ទាំងការវិនិយោគលើការផលិតទំនិញនាំចេញ ការផលិតថាមពល ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគលើវិស័យទេសចរណ៍ ការវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម និងការវិនិយោគលើវិស័យឧស្សាហកម្មរ៉ែផងដែរ ដែលជាវិស័យមួយសំរាប់ជួយបង្កើនដល់សេដ្ឋកិច្ចប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ននេះ។ ស្របពេលជាមួយគ្នានេះដែរ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី02 របស់រាជរដ្ឋាភិបាលកម្ពុជាក៏បានផ្តល់អាទិភាពខ្ពស់ដល់ការធ្វើវិនិយោគទាំងក្នុង និងក្រៅស្រុកទៅលើវិស័យធនធានធម្មជាតិ (រ៉ែ)។

បន្ថែមពីលើសក្តានុពលផ្នែកនយោបាយ និងភាពអំណោយផលផ្នែកធនធានធម្មជាតិ ព្រះរាជាណាចក្រកម្ពុជាក៏មានសក្តានុពលទៅលើផ្នែកផលិតកម្មកសិកម្ម កសិ-ឧស្សាហកម្ម និងផលិតកម្មឧស្សាហកម្មលោហៈធាតុដូចជា រ៉ែមាស រ៉ែត្បូង រ៉ែដែកជាដើម។ គួរកត់សំគាល់ផងដែរថា តំបន់ភូមិភាគឥសាននៃប្រទេស គឺជាតំបន់មួយដែលផ្តល់នូវធនធានរ៉ែជាច្រើនប្រភេទ។

ដើម្បីឆ្លើយតបនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយវិស័យវិនិយោគលើធនធានរ៉ែ ខេត្តរតនគិរីក៏បានដាក់ចេញនូវផែនការ និងគោលដៅដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្ត សំដៅធ្វើយ៉ាងណាឱ្យមានកំនើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋ តាមរយៈការបង្កើនកាលានុវត្តភាពការងារ ការវិនិយោគឯកជន និងសាធារណៈ និងការពង្រីកផលិតកម្មសេវាកម្មប្រកបដោយចីរភាព។ គោលដៅចំបង គឺផ្តោតសំខាន់លើការអភិវឌ្ឍន៍វិស័យធនធានរ៉ែ ជាពិសេសការធ្វើអាជីវកម្មទៅលើធនធានរ៉ែទាំងនេះឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងទទួលបានសមិទ្ធិផលខ្ពស់ និងឱ្យអស់លទ្ធភាព ជាជាងទុកតំបន់នេះឱ្យនៅជាដីព្រៃរិចរិល ដែលមិនបានផ្តល់ប្រយោជន៍ និងប្រាក់ចំណូលច្រើន។ ទន្ទឹមនឹងនោះដែរ ការកសាងសមត្ថភាពផ្នែកបច្ចេកទេសរុករក និងធ្វើអាជីវកម្មរ៉ែ ក៏បានផ្សព្វផ្សាយនៅក្នុងពេលតែមួយដល់ភាគីពាក់ព័ន្ធទាំងអស់ដែរ។

ដោយមើលឃើញនូវភាពអនុគ្រោះផ្នែកនយោបាយ និងភាពអំណោយផលផ្នែកធម្មជាតិ ក៏ដូចជាដើម្បីរួមចំណែកជួយសំរេចឱ្យបាននូវគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន Hoang Anh Rattanakiri Co., Ltd. បានស្នើសុំសម្បទានដីសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលក្នុងទំហំផ្ទៃដី ១៩៤ហ.ត. ដែល

មានទីតាំងស្ថិតនៅស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ខេត្តរតនគីរី ដើម្បីធ្វើការអភិវឌ្ឍន៍លើវិស័យធនធានរ៉ែដែក សំរាប់បំពេញតំរូវការប្រើប្រាស់ដែកក្នុងស្រុក និងនាំចេញទៅទីផ្សារអន្តរជាតិ ។

## ១.២. គោលបំណងនៃការរៀបចំរបាយការណ៍

ជាការពិតណាស់ រាល់ការអភិវឌ្ឍន៍តែងតែមានការប៉ះពាល់ គ្រាន់តែការប៉ះពាល់នោះមានកំរិតខុស១គ្នាប៉ុណ្ណោះ ។ បទពិសោធន៍ជាច្រើនបានបង្ហាញឱ្យឃើញថា ប្រសិនបើហេតុប៉ះពាល់នៃគំរោងអភិវឌ្ឍន៍មួយត្រូវបានធ្វើអត្តសញ្ញាណ ព្យាករណ៍ និងវាយតំលៃត្រឹមត្រូវ ហើយវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានត្រូវបានគិតគូរទុកជាមុន និងរៀបចំជាផែនការគ្រប់គ្រងបរិស្ថានសមស្រប តាមរយៈការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន នោះការប៉ះពាល់អវិជ្ជមានមួយចំនួនធំពិតជាអាចចៀសវាង ឬកាត់បន្ថយ ឬស្តារឡើងវិញ ឬសង/ប៉ះប៉ូវបាន ។ ផ្ទុយទៅវិញ ប្រសិនបើគំរោងអភិវឌ្ឍន៍មួយដំណើរការដោយមិនបានធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គម ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងគតិយុត្តទេនោះ ម្ចាស់គំរោងពិតជាបានបាត់បង់នូវឱកាសផ្សេង១ដើម្បីគ្រប់គ្រង និងកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលក្នុងករណីមួយចំនួនបានបង្កឱ្យមានបញ្ហាធ្ងន់ធ្ងរផ្សេង១ដល់ធនធានបរិស្ថានរូបសាស្ត្រ ជីវសាស្ត្រ និងសង្គម និងនាំឱ្យមានការរអាក់រអួលក្នុងការអនុវត្តគំរោង ជាពិសេសអាចប៉ះពាល់ធ្ងន់ធ្ងរដល់គំរោងវិនិយោគរបស់ខ្លួន (ឧ. ការផ្អាកដំណើរការសកម្មភាព ឬបិទគំរោងអាជីវកម្មជាដើម) ។

ដោយយល់ច្បាស់អំពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គម ក៏ដូចជាដើម្បីបំពេញនូវតំរូវការផ្លូវច្បាប់ (ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (1996) ក៏ដូចជាអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (1999)) ការសិក្សាលើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមដំបូងនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បី:

- ពិនិត្យឡើងវិញ និងពិភាក្សាអំពីក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងគំរោងក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មរ៉ែនេះ ។
- សិក្សាលើធនធានបរិស្ថានដែលមានស្រាប់ដូចជា ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ច-សង្គម ។
- ធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីប្រមូលនូវមតិយោបល់ កង្វល់ និងអនុសាសន៍-សំណូមពររបស់ប្រជាពលរដ្ឋក្នុងតំបន់ អាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ។
- វិភាគពីការប៉ះពាល់បរិស្ថាន-សង្គមនានា ដែលអាចនឹងបង្កឡើងដោយសកម្មភាពគំរោង ។
- រិះរកនូវវិធានការកាត់បន្ថយសមស្របនានាដើម្បីចៀសវាង កាត់បន្ថយ ស្តារឡើងវិញ ឬធ្វើជាសំណង/ប៉ះប៉ូវនូវការប៉ះពាល់ដែលបានរកឃើញ និងរៀបចំជាផែនការគ្រប់គ្រងបរិស្ថានសមស្របមួយសំរាប់ឱ្យម្ចាស់គំរោងយកទៅអនុវត្ត ក៏ដូចជាសំរាប់ឱ្យស្ថាប័នជំនាញពាក់ព័ន្ធនានាធ្វើការអង្កេតតាមដាន ។

Draft

❖ ធ្វើការសន្និដ្ឋានរួមអំពីហេតុប៉ះពាល់បរិស្ថាន-សង្គមនៃគំរោងអភិវឌ្ឍន៍នេះ ព្រមទាំងលើកឡើងនូវអនុសាសន៍ចាំបាច់នានាពាក់ព័ន្ធនឹងដំណើរការនៃគំរោងនេះ។

## ១.៣. វិធីសាស្ត្រ និងទំហំនៃការសិក្សា

វិធីសាស្ត្រក្នុងការសិក្សាលើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមដំបូង សំរាប់គំរោងធ្វើអាជីវកម្មរ៉ែដែករបស់ក្រុមហ៊ុន Hoang Anh Rattanakiri Co., Ltd. ដែលស្ថិតនៅក្នុងស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី មានដូចតទៅ:

### ១.៣.១. ការសិក្សាលើធនធានបរិស្ថាន-សង្គមដែលមានស្រាប់នៅក្នុងតំបន់គំរោង

ផ្អែកតាមគោលការណ៍ណែនាំទូទៅ សំរាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមរបស់ក្រសួងបរិស្ថាន (2009) ការសិក្សាលើធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គំរោងផ្តោតសំខាន់លើ03ផ្នែក: ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ច-សង្គម។ ទិន្នន័យចាំបាច់នានាសំរាប់ការសិក្សានេះ ត្រូវបានប្រមូលតាមវិធីសាស្ត្រចំនួនពីរសំខាន់ៗ :

#### ១.៣.១.១. ការប្រមូលទិន្នន័យដែលមានស្រាប់ (Secondary Data)

ទិន្នន័យពាក់ព័ន្ធនឹងធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ច-សង្គមមួយចំនួន ត្រូវបានសិក្សា និងប្រមូលចងក្រងជាឯកសារ ហើយឯកសារទាំងនេះមានតំកល់ទុកនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងវិទ្យាស្ថានស្រាវជ្រាវនានា ក៏ដូចជាព័ត៌មានផ្សព្វផ្សាយនៅតាមកាសែត និងគេហទំព័រ (Websites) ផ្សេងៗ។ ដោយការសិក្សានេះគ្រាន់តែជាការសិក្សាដំបូងលើហេតុប៉ះពាល់បរិស្ថាន-សង្គម ក៏ដូចជាដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាពនូវទិន្នន័យដែលមានស្រាប់ ចៀសវាងការសិក្សាដដែលៗលើបញ្ហាតែមួយ និងសន្សំសំចៃថវិកា ទិន្នន័យពាក់ព័ន្ធនានាដូចជា ដី (ភូគព្ភសាស្ត្រ សណ្ឋានដី/ឋានលេខា ប្រភេទដី) អាកាសធាតុ (សីតុណ្ហភាព សំណើម របបខ្យល់ និងទឹកភ្លៀង) គំរបព្រៃឈើ ប្រភេទសត្វ-រុក្ខជាតិ ក៏ដូចជាទិន្នន័យពាក់ព័ន្ធនឹងប្រជាសាស្ត្រ ការតាំងទីលំនៅ មុខរបរ (ប្រភពចំណូលសំខាន់ៗ និងបន្ទាប់បន្សំ) ការប្រើប្រាស់ដី-ទឹក-ថាមពល ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ សុខភាព និងសុខមាលភាពសាធារណៈ សម្បត្តិវប្បធម៌ (សំណង់ប្រវត្តិសាស្ត្រ ប្រាសាទ បុរាណ វត្តអារាម/ទំនៀមទំលាប់ ប្រពៃណី ឬជនជាតិភាគតិចជាដើម) និងតំបន់ទេសចរណ៍ ត្រូវបានប្រមូលពីបណ្ណាល័យរបស់ក្រសួងបរិស្ថាន នាយកដ្ឋាន EIA (Environmental Impact Assessment) អង្គការ JICA ប្រចាំនៅកម្ពុជា (Japan International Coopera-tion Agency) វិទ្យាស្ថានស្រាវជ្រាវការអភិវឌ្ឍកម្ពុជា (Cambodia Development

Draft

Resource Institute) អាជ្ញាធរឃុំដែលពាក់ព័ន្ធ គេហទំព័ររបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធនានាដូចជា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង ឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ និងក្រសួងកសិកម្មជាដើម ។

### ១.៣.១.២. ការប្រមូលទិន្នន័យដើម (Primary Data)

ការប្រមូលទិន្នន័យដើមត្រូវបានធ្វើឡើងចំពោះតែទិន្នន័យណាដែលមិនទាន់សិក្សា និងចងក្រងរួចជាឯកសារ ។ វិធីសាស្ត្រសំខាន់ៗដែលបានប្រើប្រាស់ក្នុងការប្រមូលទិន្នន័យដើមពាក់ព័ន្ធមានដូចតទៅ:

- **ធនធានរូបសាស្ត្រ:** ទិន្នន័យដើមដែលចាំបាច់មានដូចជា គុណភាពខ្យល់ សំលេង-រំញ័រ ប្រព័ន្ធផ្លូវទឹក និងគុណភាពទឹក (ទឹកលើដី និងក្រោមដី) នៅក្នុងតំបន់គំរោង។ ការប្រមូលទិន្នន័យទាំងនេះ ជាទូទៅត្រូវបានធ្វើឡើងតាមរយៈការចុះសង្កេតផ្ទាល់ និងការពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងតំបន់ និងមន្ទីរ-ស្ថាប័នពាក់ព័ន្ធនានា។ ផែនទី JICA (2002) និងរដ្ឋបាលព្រៃឈើ (2005) ក៏ត្រូវបានប្រើប្រាស់ផងដែរ សំរាប់ជាជំនួយដល់ការសិក្សាអំពីប្រព័ន្ធផ្លូវទឹកនៅក្នុងតំបន់គំរោង។
- **ធនធានជីវសាស្ត្រ:** ទិន្នន័យដើមដែលចាំបាច់មានដូចជា ស្ថានភាពព្រៃឈើ (ផ្ទៃដី ប្រភេទព្រៃ មាឌឈើឈរ ប្រភេទសត្វ-រុក្ខជាតិ) ជីវៈចំរុះ និងប្រព័ន្ធអេកូឡូស៊ី (ទីជំរក និងប្រព័ន្ធដីសើម) នៅក្នុងតំបន់គំរោង។ ការសិក្សាអំពីស្ថានភាពព្រៃឈើ ត្រូវបានធ្វើឡើងដោយការប្រើប្រាស់វិធីសាស្ត្រនៃការធ្វើសារពើភ័ណ្ឌព្រៃឈើ ដែលក្នុងនោះ ផែនទីគំរបព្រៃឆ្នាំ2006របស់រដ្ឋបាលព្រៃឈើ/បរិស្ថាន ត្រូវបានប្រើប្រាស់ផងដែរសំរាប់ជាជំនួយដល់ការសិក្សា។ ការសាកសួរ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងតំបន់ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ (ដូចជា សាលាស្រុក ការិយាល័យបរិស្ថានស្រុក ទីស្នាក់ការដែនជំរកសត្វព្រៃសំឡូត អ្នកជំនាញរបស់រដ្ឋបាលព្រៃឈើជាដើម) អំពីស្ថានភាព និងការប្រែប្រួលនៃព្រៃឈើ និងសត្វព្រៃក្នុងរយៈពេលប្រមាណ05–10ឆ្នាំ ចុងក្រោយក៏ត្រូវបានធ្វើឡើងផងដែរដើម្បីប្រមូលយកនូវព័ត៌មានបន្ថែម ។
- **ស្ថានភាពសេដ្ឋកិច្ច-សង្គម:** ទោះបីជាទិន្នន័យពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ច-សង្គមនានា ស្ទើរតែបានចងក្រងជាឯកសារ-ព័ត៌មាននៅតាមឃុំដែលពាក់ព័ន្ធនានាក៏ដោយ ការសិក្សានេះបានអនុវត្តនូវវិធីសាស្ត្រមួយចំនួនទៀតដូចជា ការចុះសង្កេតផ្ទាល់ និងការសំភាសន៍ជាលក្ខណៈបុគ្គល (Personal Interview) ក៏ដូចជាការជួបប្រជុំពិភាក្សាជាមួយក្រុមគោលដៅ (Focus Group Discussion) ដើម្បីផ្ទៀងផ្ទាត់នឹងទិន្នន័យដែលមានស្រាប់ និងធ្វើការសិក្សាបន្ថែម ជាពិសេសទៅលើរបៀបរបបនៃការរស់នៅ មុខរបរ ប្រាក់ចំណូល និងទំនៀមទំលាប់ប្រពៃណីរបស់ជនជាតិផ្សេងៗជាដើម ។

Draft

### ១.៣.២. ការវិភាគពីហេតុប៉ះពាល់បរិស្ថាន និងការជ្រើសរើសវិធានការកាត់បន្ថយ

ការវិភាគពីការប៉ះពាល់បរិស្ថាន-សង្គម ត្រូវបានធ្វើឡើងដោយប្រើប្រាស់នូវវិធីសាស្ត្រជាច្រើនយ៉ាងដូចជា:

- Checklist: ជាតារាងមួយដែលបានណែនាំអោយប្រើជាផ្លូវការដោយប្រកាសលេខ376ប្រក.បស្ថ ចុះថ្ងៃទី02 ខែកញ្ញា ឆ្នាំ2009 របស់ក្រសួងបរិស្ថាន។ ការវិភាគពីការប៉ះពាល់ត្រូវធ្វើឡើងជាបីដំណាក់កាល( មុនប្រតិបត្តិគំរោង ប្រតិបត្តិគំរោង និងបញ្ចប់គំរោង) ហើយសមាសភាគធនធានបរិស្ថាន-សង្គម ដែលត្រូវយកមកពិចារ-ណាក្នុងដំណាក់កាលនីមួយៗរួមមាន ធនធានជីវសាស្ត្រ ធនធានរូបសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ច-សង្គម ។
- Matrix: ជាតារាងសំរាប់ធ្វើអត្តសញ្ញាណ អំពីអន្តរអំពើរវាងសកម្មភាពគំរោង( ដែលដាក់បង្ហាញនៅក្នុងជួរណាមួយនៃតារាង) និងសមាសភាគធនធានបរិស្ថាន (ដែលដាក់បង្ហាញនៅក្នុងជួរមួយទៀតនៃតារាង) (UNEP 2002) ។
- Overlay & Geographic Information System (GIS): ជាវិធីសាស្ត្រមួយដែលប្រើប្រាស់ប្រព័ន្ធ GIS ដើម្បី ប្រមូលនូវព័ត៌មានផ្សេងៗទាក់ទងនឹងស្ថានភាពភូមិសាស្ត្រ អេកូឡូស៊ី និងសេដ្ឋកិច្ច-សង្គម រួចដាក់បញ្ចូលព័ត៌មានទាំងអស់នេះនៅលើផែនទីតែមួយ ក្នុងគោលបំណងកំណត់នូវសក្តានុពលនៃការប៉ះពាល់ផ្សេងៗ ដែលបណ្តាលមកពីអន្តរអំពើរវាងស្ថានភាពទាំងនេះ (UNEP 2002) ។
- Expert System & Professional Judgement: ជាវិធីសាស្ត្រមួយនៃការវិភាគហេតុផលនៃការប៉ះពាល់ដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍ផ្សេងៗរបស់អ្នកជំនាញ (UNEP 2002) ។

ការជ្រើសរើសវិធានការកាត់បន្ថយ ត្រូវបានធ្វើឡើងដោយពិចារណា ទៅលើលំដាប់នៃវិធានការកាត់បន្ថយ (Mitigations): ចៀសវាង (Avoid) កាត់បន្ថយ (Minimize) ស្តារឡើងវិញ (Restore) និងសំណង/ប៉ះប៉ូវ (Compensate/Offset) ដែលបានណែនាំឱ្យប្រើប្រាស់ ដោយសមាគមន៍អន្តរជាតិស្តីពីការវាយតំលៃផលប៉ះពាល់ (International Association for Impact Assessment – IAIA) ។ ការលើកឡើងនូវវិធានការតាមរបៀបនេះ គឺដើម្បីធានាឱ្យបានថាការប៉ះពាល់ដែលនៅសេសសល់ស្ថិតនៅក្នុងកំរិតមួយដែលអាចទទួលយកបាន និងដើម្បីបង្កើនផលប្រយោជន៍ផ្អែកបរិស្ថាន និងសង្គម ។

Draft

### ១.៣.៣. ការរៀបចំរបាយការណ៍

ការរៀបចំរបាយការណ៍ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមដំបូងសំរាប់គំរោងនេះ ត្រូវបានធ្វើឡើងដោយផ្អែកលើគោលការណ៍ណែនាំទូទៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមដំបូង និងពេញលេញដែលបានអនុម័ត និងប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយក្រសួងបរិស្ថានចាប់ពីថ្ងៃទី02 ខែកញ្ញា ឆ្នាំ2009 និងមានការកែប្រែខ្លះទៅតាមស្ថានភាពជាក់ស្តែងនៃលក្ខណៈ និងប្រភេទគំរោងនេះ។

Draft